**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៦៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបំពេញបន្ថែម មាត្រា៥ ជំពូកទី២ មាត្រា៣៧ ជំពូកទី៨ នៃអនុក្រឹត្យលេខ១២ អនក្រ.បក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីឯកសណ្ឋាន ស្លាកសញ្ញា និងទង់ជ័យ នៃកងយោធពលខេមរភូមិន្ទ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ២៩អនក្រ.បក ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០២ ស្តីពីបទវិន័យទូទៅសម្រាប់កងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ.បក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពី ឯកសណ្ឋាន ស្លាកសញ្ញា និងទង់ជ័យ នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៣០៤ អនក្រ.បក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលមាត្រា ៣២ មាត្រា៣៦ និងមាត្រា៤០ នៃអនុក្រឹត្យលេខ១២ អនក្រ.បក ចុះថ្ងៃទី០១ខែកុម្ភៈ ឆ្នាំ២០១៧ និងមាត្រា ១៣ថ្មី នៃអនុក្រឹត្យលេខ ២២១ អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីឯកសណ្ឋាន ស្លាកសញ្ញា និងទង់ជ័យ នៃកងយោធពលខេមរភូមិន្ទ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រាមួយ .~**

ត្រូវបានបំពេញបន្ថែម មាត្រា៥ ជំពូកទី២ មាត្រា៣៧ ជំពូកទី៨ នៃអនុក្រឹត្យលេខ១២ អនក្រ.បក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីឯកសណ្ឋាន ស្លាកសញ្ញា និងទង់ជ័យនៃកងយោធពលខេមរភូមិន្ទ ត្រូវបាន រៀបចំដូចខាងក្រោម៖

**មាត្រា៥ .~ ថ្មី**

ត្រូវបានរៀបចំបន្ថែមឯកសណ្ឋានលេខ៣ដៃវែង សម្រាប់កងទ័ពជើងគោក កងទ័ពជើងទឹក កងទ័ពជើងអាកាស និងកងរាជអាវុធហត្ថ ដែលមានរូបភាព និងគំរូដូចខាងក្រោម៖

- ខោ អាវ និងមួកកាស្កេតពណ៌តាមប្រភេទទ័ព

- អាវដៃវែង កឱប ខាងក្រោយមានផែក និងប៉ានចង្កេះនៅខាងក្រោយ ផ្នែកខាងមុខមានហោប៉ៅបួន ខាងលើ២ ដេរប៉ះ ចាប់ផ្នត់មួយចំកណ្តាល មានគម្របរាងស្លឹកពោធិ៍ និងខាងក្រោម២ ដេរបង្កប់ មានគម្រប រាងស្លឹកពោធិ៍ មានប៊ូលស្នាដាក់ឡេវជ័រ មានអង្កត់ផ្ចិត១៤ម.ម។ ចាប់ពីកអាវមកដល់ក្រោមមានឡេវចំនួន៦គ្រាប់ មានរូបព្រះសង្ការពណ៌មាស ធ្វើពីលោហធាតុ មានអង្កត់ផ្ចិត២០ម.ម ឡេវហោប៉ៅលើ ២គ្រាប់មានអង្កត់ផ្ចិត ១៥ម.ម និងឡេវហោប៉ៅក្រោម ២គ្រាប់មានអង្កត់ផ្ចិត ១៨ម.ម មានរូបព្រះសង្ការពណ៌មាស ធ្វើពីលោហធាតុ

- ដៃអាវវែងកាត់រាងបំពង់ ដេរប៉ាននៅចុងដៃរាងជារង្វង់ ប្រវែងពីចុងដៃអាវចំនួន៨០ម.ម និងមានដាក់ ឡេវបញ្ឆោត ៤គ្រាប់ រូបព្រះសង្ការទំហំ ១៥ម.ម ធ្វើពីលោហធាតុ ពណ៌មាស រៀបបញ្ឈរតាមដៃអាវ

- ខោជើងវែងកាត់ដូចខោឯកសណ្ឋានលេខ៤។

ចំពោះនារីអាវមានគំរូដូចបុរស និងសំពត់ហ្ស៊ីបពណ៌តាមប្រភេទទ័ពសម្រុងក្រោមក្បាលជង្គង់។

**ឯកសណ្ឋានលេខ៣ដៃវែង សម្រាប់កងទ័ពជើងគោក កងទ័ពជើងទឹក កងទ័ពជើងអាកាស និងកងរាជ អាវុធហត្ថ មានគំរូដូចក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។**

**មាត្រា៣៧ .~ ថ្មី**

ត្រូវបានបំពេញបន្ថែម ទង់កងកិត្តិយសសម្រាប់បដិសណ្ឋារកិច្ច ព្រះមហាក្សត្រ ប្រធានាធិបតី ប្រមុខរដ្ឋ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី ជាតិ-អន្តរជាតិមានរូបភាព និងខ្នាតដូចខាងក្រោម៖

**+ រូបភាព និងខ្នាត**

យកគំរូទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា រាងចតុកោណកែង បណ្តោយប្រវែង ១៧៨ស.ម និងទទឹង ១៣៥ស.ម។ ដងទង់ប្រវែង២៨៥ស.ម ធ្វើពីលោហធាតុ ឬឈើ ពណ៌ស មានទំហំអង្កត់ផ្ចិត៤ស.ម។ ក្បាលដង ទង់ខាងលើឆ្លាក់រូបព្រហ្មមុខបួន កម្ពស់២៥ស.ម ធ្វើពីលោហធាតុពណ៌មាស។ នៅក្បាលដងទង់មានរំយោល ចងក្បាលដងទង់ពីរ ពណ៌មាស មួយប្រវែង៤០ស.ម និងមួយទៀតប្រវែង៥០ស.ម។ នៅជាយទង់មាន រំយោល ពណ៌មាសព័ទ្ធជុំវិញចំនួនបីជ្រុង រំយោលមានប្រវែង៣ស.ម។

**+ ការប្រើប្រាស់**

ទង់នេះត្រូវប្រើប្រាស់សម្រាប់ពិធីបដិសណ្ឋារកិច្ច និងពិធីវន្ទនៈកិច្ចនានាថ្វាយ-ជូន ព្រះមហាក្សត្រ ប្រធានាធិបតី ប្រមុខរដ្ឋ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី ជាតិ-អន្តរជាតិ។

**រូបភាពទង់មានគំរូដូចក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។**

**មាត្រា៣ ៈ**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ៦កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២ ខែឧសភា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**នាយករដ្ឋមន្ត្រី** សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ សីហា**

**កន្លែងទទួលៈ**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ